**ប្រការ ៨** : កំណត់យកថ្ងៃសុក្រទី ២២ សៅរ៍ទី ២៣ អាទិត្យទី២៤ ខែ មីនា ឆ្នាំ ១៩៩៦ ជាទិវាកីឡាជនពិការកម្ពុជា ប្រចាំឆ្នាំ ១៩៩៦ ។

**ប្រការ ៩** : អធិបតីកិត្តិយស សមាជិកកិត្តិយស ទីប្រឹក្សា លេខាធិការ អនុគណៈកម្មការប្រតិបត្តិ ចូលរួមក្នុងកម្មវិធីតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការរៀបចំ ទិវាកីឡាជនពិការកម្ពុជា ។

**ប្រការ ១០** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ - គណៈកម្មការរៀបចំទិវាកីឡាកម្ពុជា

ប្រធាន

ហត្ថលេខា និង ត្រា

**ហ៊ុន លីហួត**

* * *

## ៨ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០១៣ បទ -ប្រក**

**ស្តីអំពីការប្រើប្រាស់ប្លង់អោយលេខទូរសព្ទជាតិ**

**រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃ ០១/១១/៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា។

- បានឃើញអនុក្រឹត្យលេខ ០៥ អ ន ក្រ ចុះថ្ងៃទី ៥/០៣/១៩៨៧ ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានឃើញសំនូមពរចុះថ្ងៃទី ០២/០២/១៩៩៦ របស់នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ។
- បានឃើញសំនូមពរចាំបាច់

**សម្រេច**

**ប្រការ ១** : អនុញ្ញាតការប្រើប្រាស់គំរោងលេខ CMB/93/006 ផ្នែកមួយក្នុង «ប្លង់មេ» ដែលរៀបចំឡើងដោយជំនួយសហប្រតិបត្តិការនៃអង្គការ ITU/UNDP សំរាប់ជា«ប្លង់អោយលេខទូរសព្ទជាតិចល័ត» តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម÷

១.១ បណ្តាញទូរសព្ទចល័តនិង អចល័ត និងទូរសព្ទឥតប្រើខ្សែក្នុងតំបន់ក្រុងភ្នំពេញ និង បណ្តាខេត្ត បច្ចុប្បន្នកំពុងបំរើសេវា ត្រូវរៀបបញ្ចូលតាម «ប្លង់អោយលេខ» ដោយព្រមៗគ្នាតាមសេចក្តីជូន ដំណឹងរបស់ក្រសួង ប,ទ ។

១.២ លេខពិសេស ឬសេវាពិសេសទាំងឡាយ ជាអាទិ៍ សេវាទូរសព្ទការីត្រូវកំណត់ដោយឡែក ដោយក្រសួងប.ទ និងក្រោយពេល «ប្លង់មេ» បានសំរេច ។

១.៣ សេវាវិទ្យុលេខសញ្ញាសេវាបរិមូល ( value added service) និងសេវាថ្មី ។ ដទៃទៀត និង ត្រូវកំណត់ដោយក្រសួង ប.ទ នៅពេលក្រោយ ។

**ប្រការ ២** : ប្លង់អោយលេខទូរសព្ទជាតិ កំណត់ចំនួនខ្ទង់ ឬប្រវែងខ្ទង់លេខចំនួន «ប្រាំបីខ្ទង់» ជាលេខទូរសព្ទជាតិ (Natoinal significant Number) គឺ «ពីរខ្ទង់» ជាលេខកូដតំបន់ ឬ ជាលេខកូដការី និង «ប្រាំមួយខ្ទង់» ជាលេខទូរសព្ទ ។

២.១ លេខកូដការី ត្រូវប្រើសំរាប់ហៅលេខទូរស័ព្ទចល័តក្នុងប្រព័ន្ធជាមួយគ្នា ។ ប្រព័ន្ធនីមួយៗដែលមានសេវាតាមខេត្តហើយត្រូវស្ថាបនាមជ្ឈមណ្ឌលទូរសព្ទចលតសំរាប់តំបន់នោះ ។

២.២ ហៅទូរសព្ទពីប្រពន្ធទូរស័ព្ទ ចល័តមួយទៀតត្រូវហៅលេខកូដ «០» លេខកូដការី និងលេខទូរសព្ទ ចលត ។

**ប្រការ ៣ :** ការគិតថ្លៃសន្ទនាការទូរសព្ទ សន្ទនាក្នុងក្រុង ក្នុងតំបន់ ឆ្លងតំបន់ ... សន្ទនា អន្តរជាតិ ត្រូវផ្អែកតាមលេខទូរសព្ទអ្នកហៅនិងអ្នកទទួល ដែលមានស្ថានភាពក្នុងប្លង់អោយលេខទូរសព្ទជាតិ ។

៣.១ ភាពចល័តនៃសេវាទូរសព្ទចលត និង ត្រូវបានកំណត់ដោយឡែកដោយក្រសួង ប. ទ ។

៣.២ សន្ទនាការទូរសព្ទឆ្លងបណ្តាញ ឬ ឆ្លងប្រពន្ធ និង ត្រូវបានកំណត់ដោយក្រសួង ប. ទ តាមប្រភេទជាក់ស្តែង ។

**ប្រការ ៤ :** ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណៈនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ គ្រប់មន្ទីរ ប.ទខេត្តក្រុង បណ្តាញក្រុមហ៊ុនសេវាទូរសព្ទ បណ្តាក្រុមហ៊ុនវិទ្យុលេខសញ្ញា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**សុះ ឈុន**

* * *

# តារាងសង្ខេបនៃលេខតំបន់សំរាប់ប្រើក្នុងប្រព័ន្ធទូរស័ព្ទ

| ខេត្ត | លេខតំបន់សំរាប់ប្រើ ជាមួយទូរស័ព្ទអចល័ត | លេខទូរស័ព្ទចល័ត Samart | លេខទូរស័ព្ទចល័ត Tricelcam | លេខទូរស័ព្ទចល័ត Camtel |
|---|---|---|---|---|
| Banteay Meanchey | 054 | 015 54x xxx | 017 54x xxx | 018 54x xxx |
| Battambang | 053 | 015 53x xxx | 017 53x xxx | 018 53x xxx |
| Kampong cham | 042 | 015 42x xxx | 017 42x xxx | 018 42x xxx |
| Kampong chhang | 026 | 015 26x xxx | 017 26x xxx | 018 26x xxx |
| Kampong speu | 025 | 015 25x xxx | 017 25x xxx | 018 25x xxx |
| Kampong Thom | 062 | 015 62x xxx | 017 62x xxx | 018 62x xxx |
| Kampot | 033 | 015 33x xxx | 017 33x xxx | 018 33x xxx |
| Kandal | 024 | 015 24x xxx | 017 24x xxx | 018 24x xxx |
| Kep | 036 | 015 36x xxx | 017 36x xxx | 018 36x xxx |
| Koh Kong | 035 | 015 35x xxx | 017 35x xxx | 018 35x xxx |
| Kratie | 072 | 015 72x xxx | 017 72x xxx | 018 72x xxx |
| Mondul Kiri | 073 | 015 73x xxx | 017 73x xxx | 018 73x xxx |
| Phnom Penh | 023 | 015 8xx xxx | 017 8xx xxx | 018 8xx xxx |
| Preah Vihear | 064 | 015 64x xxx | 017 64x xxx | 018 64x xxx |
| Prey Veng | 043 | 015 43x xxx | 017 43x xxx | 018 43x xxx |
| Pursat | 052 | 015 52x xxx | 017 52x xxx | 018 52x xxx |
| Ratanak Kiri | 075 | 015 75x xxx | 017 75x xxx | 018 75x xxx |
| Siem Reap | 063 | 015 63x xxx | 017 63x xxx | 018 63x xxx |
| Sihanoukville | 034 | 015 34x xxx | 017 34x xxx | 018 34x xxx |
| Rtung Treng | 074 | 015 74x xxx | 017 74x xxx | 018 74x xxx |
| Svay Rieng | 044 | 015 44x xxx | 017 44x xxx | 018 44x xxx |
| Takeo | 032 | 015 32x xxx | 017 32x xxx | 018 32x xxx |
| Udor Meanchey | 065 | 015 65x xxx | 017 65x xxx | 018 65x xxx |

**កំណត់ចំណាំ :** លេខទូរស័ព្ទចល័តនៅតាមបណ្តាខេត្តនឹងត្រូវចាប់ផ្តើមដូរពីថ្ងៃទី ១មេសា ៩៦ទៅ